# ការសម្ភាសរបស់អ្នកមីង ឃិន សុជីវនី

កៈ អ្នកសម្ភាសឈ្មោះ ហែម សីហា ខៈ អ្នកត្រូវបានសម្ភាសឈ្មោះ ឃិន សុជីវនី

## <u>ការសង្ខេបរបស់អ្នកមីង ឃិន សុជីវនី</u>

ការសង្ខេបពីខ្ញុំបាទ សីហា ខ្ញុំដឹងថាអ្វីទាំងអស់ដែលអ្នកមីង ឃិន សុជីវនី បានចែកចាយជាមួយខ្ញុំបាទ គឺជាការពិតដែលបានកើតឡើងក្នុងឆាកជីវិតរបស់អ្នកមីងមែន។ ខ្ញុំពិតជាមានអារម្មណ៍ក្តុកក្តួលនៅពេលបានដឹងជីវប្រវត្តិដ៏កំសត់របស់អ្នកមីង ជាពិសេសនៅពេលដែលខ្ញុំបានដឹងថា សឹងតែពេញមួយជីវិតរបស់អ្នកមីង គឺអ្នកមីងបានជួបតែរឿងពិបាកៗ ឧបសគ្គមិនចេះចប់មិនចេះហើយ មិនតែប៉ុណ្ណោះ អ្នកមីងត្រូវបានបាត់បង់បងប្អូនបង្កើតទាំងអស់ក្នុងសម័យពលពតទៀត។ ប៉ុន្តែទោះបីជាអ្នកមីងបានជួបនូវរឿងពិបាកៗដ៏ច្រើនក្នុងជីវិតក៏ពិតមែន តែអ្នកមីងមិនដែលរាថយនូវរឿងទាំងអស់នោះដែរ គឺអ្នកមីងស៊ូជំនះលើវាគ្រប់ពេលវេលាទាំងអស់។ ហើយមានរឿងមួយទៀតដែលធ្វើឲខ្ញុំបាទ មានសេចក្តីអំណរចំពោះអ្នកមីងនោះ គឺអ្នកមីងបានស្គាល់ដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ហើយអ្នកមីងបាននឹងកំពុងរស់នៅដោយព្យាយាមគោរពបទបញ្ញាតិរបស់ព្រះយេស៊ូវគ្រីស្ទ និងធ្វើជាគំរូដល់កូនរបស់អ្នកមីងទៀតផង។

កៈ ជំរាបសួរអ្នកមីង!

ខៈ ចា៎! ជំរាបសួរ!

កៈ អឺ! ថ្ងៃនេះខ្ញុំបាទឈ្មោះ ហែម សីហា សូមធ្វើកិច្ចសម្ភាសដល់អ្នកមីងស្រីម្នាក់ ដែលសព្វថ្ងៃគាត់កំពុងរស់នៅភូមិបី សង្កាត់ បឹងសាឡាងអឺ! ខណ្ឌ ទួលគោក នៅក្នុងរាជធានីភ្នំពេញ។ ហើយក៏ត្រូវថ្ងៃទីអឺ! ២៨ អឺ! ត្រូវថ្ងៃអាទិត្យ ខែ មករា ឆ្នាំ ២០១៨។ ហើយអ្នកមីងអត់ទោសថ្ងៃនេះក្មួយសំអឺ! ធ្វើកិច្ចសម្ភាសអ្នកមីង ហើយកិច្ចសម្ភាសនេះគឺ ជាគម្រោងរបស់សាលាមានឈ្មោះថា BYU ហើយ BYU ហ្នឹងមានឈ្មោះពេញ សាលាសាកលវិទ្យាល័យ Brigham Young University ហើយគម្រោងនេះផងដែរមានឈ្មោះថា គម្រោងប្រវត្តិផ្ទាល់ខ្លួនរបស់ប្រជាជនកម្ពុជា ហើយក្មួយដឹងថាគម្រោងនេះនឹងជួយដល់ក្រុមគ្រួសារអ្នកមីង ជាពិសេសអឺ! អ្នកមីងអាចថែរក្សាកំណត់ហេតុនេះ ដើម្បីឲកូនរបស់មីងហើយនិងចៅៗ ពួកគេមានឪកាស

ដឹងអំពីប្រវត្តិអ្នកមីងផ្ទាល់ខ្លួន ថាអ្នកមីងបានតស៊ូអីខ្លះនៅក្នុងជីវិតហ្នឹង ដើម្បីជួយចញ្ចឹមពួកគាត់មានក្រុមគ្រួសាររហូតដល់សព្វថ្ងៃនេះ។ អញ្ចឹងអត់ទោសអ្នកមីង តើអ្នកមីងយល់ព្រមដើម្បីឲក្មួយធ្វើកិច្ចសម្ភាសអ្នកមីងទេអ្នកមីង?

ខ៖ ចាំ!

ក៖ អញ្ចឹងប្រសិនបើអ្នកមីងអឺ! យល់ព្រមខ្ញុំដឹងថាកិច្ចសម្ភាសនេះនឹងប្រទានពរជ័យដល់គ្រួសារអ្នកមីងផ្ទាល់។

ខ៖ ចាំ!

ក៖ ហើយខាងសាលានឹងផ្តល់អឺ! ថតចម្លងមួយច្បាប់នៃកិច្ចសម្ភាសនេះជា ស៊ីឌី ទៅកាន់អ្នកមីង។ អញ្ចឹងប្រសិនបើអ្នកមីងអនុញ្ញាតឲក្មួយអឺ! ធ្វើកិច្ចសម្ភាសនេះក្មួយនឹងចាប់ផ្តើមសួរសំនួរអ្នកមីងដូចតទៅ។ តើអ្នកមីងមានឈ្មោះអ្វីដែរឈ្មោះទៅតាមអត្តសញ្ញាណប័ណអ្នកមីង?

ខ៖ ឈ្មោះ យិន សុជីវនី។

ក៖ យិន សុជីវនី?

ខ៖ ចាំ!

ក៖ ចុះអ្នកមីងមានឈ្មោះហៅក្រៅទេអ្នកមីង?

ខ៖ មាន គេហៅអុំស្រី។

ក៖ អុំស្រី?

ខ៖ ហ្នឹងហើយ! អុំស្រី។

ក៖ ហើយអ្នកមីងមានដឹងថាមូលហេតុអ្វីបានគេហៅអ្នកមីងឈ្មោះអុំស្រីអញ្ចឹង?

ខ៖ ដោយសារឈ្មោះខ្ញុំពីមុនមកម្តាយឪពុកខ្ញុំអ្នកដាក់អញ្ចឹងហើយ ឈ្មោះស្រី ហើយដ៏អញ្ចឹងគេហៅខ្ញុំថាអុំស្រី អញ្ចឹងទៅ។

ក៖ អូ! អញ្ចឹងហែ! អ្នកមីង។

ខ៖ ចាំ!

កៈ តើអឺ! អ្នកមីងឆ្នាំនេះមានអាយុប៉ុន្មានហើយអ្នកមីង?

ខៈ ខ្ញុំអាយុ៥៨ឆ្នាំ។

កៈ ៥៨ឆ្នាំហើយ។ តើអ្នកមីងកើតនៅឆ្នាំណាដែរអ្នកមីង?

ខៈ ឆ្នាំ១៩៦០។

កៈ បើសិនជាយើងគិតជាឆ្នាំច័ន្ទគតិវិញត្រូវជាសត្វអីដែរអ្នកមីង?

ខៈ សត្វឆ្មា កណ្ដុរឆ្នាំចូត។

កៈ ឆ្នាំចូតហែស អ៎!

ខៈ អឺ!

កៈ អរគុណច្រើនអ្នកមីង។ អត់ទោសអ្នកមីង តើស្រុកកំណើតរបស់អ្នកមីងកើតនៅណាដែរអ្នកមីង?

ខៈ ខ្ញុំពីដើមស្រុកកំណើតខ្ញុំនៅទីក្រុងភ្នំពេញហ្នឹងហ៊្មង។

កៈ ទីក្រុងភ្នំពេញយើងហ្នឹងហ៊្មង?

ខៈ ចា៎!

កៈ ចុះស្ថិតនៅក្នុងភូមិ ឃុំ ស្រុក ស្រុកណាដែរអ្នកមីង?

ខៈ នៅម្ដុំយើងគេហៅពីដើមពីសង្គមគេហៅ ម្ដុំចុះអាកន្លែង៥២ជាន់ គេហៅម្ដុំហ្នឹងពេទ្យចិន ម្ដុំពេទ្យចិនហ្នឹងកន្លែងពេទ្យចិនហ្នឹងហ៊្មង ហើយសង្កាត់គេហៅសង្កាត់ លេខ៥ លូទឹកស្អុយ ម្ដុំហ្នឹងម្ដុំមេភ្លើង និយាយឲចំម្ដុំគុគទួលស្លែងហ្នឹងហ៊្មងផ្ទះខ្ញុំ នៅម្ដុំគុគទួលស្លែងហ្នឹងហ៊្មង។

កៈ ហ្នឹងខណ្ឌអីគេអ្នកមីង?

ខៈ អាហ្នឹងគេហៅសង្កាត់ លេខ៥ កាលហ្នឹងអត់មានខណ្ឌទេ មានតែសង្កាត់ទេជំនាន់ហ្នឹង។

កៈ អ៎!

ខៈ ហ្នឹងហើយ!

កៈ ចុះអឺ! អ្នកមីងមានបងប្អូនប៉ុន្មាននាក់ដែរអ្នកមីង?

ខ៖ ខ្ញុំមានបងប្អូនប្រាំនាក់។

ក៖ ចុះអ្នកមីងត្រូវជាកូនទីប៉ុន្មានដែរ?

ខ៖ កូនទី១។

ក៖ កូនទី១។ ចុះអឺ! បងប្អូនបួននាក់ទៀតហ្នឹង?

ខ៖ ស្លាប់ទាំងអស់។

ក៖ គាត់មានឈ្មោះអីដែរអ្នកមីង?

ខ៖ គាត់ប្អូនសុទ្ធតែប្រុសទាំងអស់។

ក៖ ហើយអ្នកមីងនៅចាំឈ្មោះពួកគាត់ទេ?

ខ៖ ចាំ!

ក៖ សូមជួយប្រាប់ឈ្មោះពួកគាត់?

ខ៖ ឈ្មោះគាត់ទីមួយ យិន សុជីវ៉ន យិន សូជីរិន យិន សុជីត្រា យិន សុជីវនឹម។

ក៖ ហើយអ្នកមីងធ្លាប់នៅជុំជាមួយពួកគាត់ទេ? តាំងពីកើតមក?

ខ៖ ហ្នឹងហើយតាំងពីកើតមកនៅជុំជាមួយគាត់ ដល់តាទៅជំនាន់ពលពតពួកគាត់ស្លាប់អស់នៅសល់ខ្ញុំម្នាក់ឯងគត់ ហើយខ្ញុំគ្មានទីពឹងហ្នឹងហើយបានថា គ្មានបងប្អូនទីពឹង។

ក៖ ហើយអ្នកមីងមាននៅចាំថ្ងៃខែឆ្នាំកំណើតអីពួកគាត់ទេអ្នកមីង?

ខ៖ ចាំ!

ក៖ សូមជួយប្រាប់បានទេអ្នកមីង?

ខ៖ ខ្ញុំទីមួយខ្ញុំកើតនៅឆ្នាំ ១៩៦០គឺខ្ញុំ ឆ្នាំ ១៩៦៨ ប្អូនខ្ញុំ ដល់ក្រោយមកទៀតបាន ៦៧ មួយម៉ាឆ្នាំរហូត៦៧ ៦៦ ៦៤ ៦៥ ហ្នឹងហើយ។

ក៖ ហើយចុះពលពតសម្លាប់ពួកគាត់មានដឹងទីកន្លែងដែលពួកគាត់ស្លាប់ហ្នឹងទេអ្នកមីង?

ខ៖ ស្លាប់នៅកន្លែងពោធិ៍សាត់។

ក៖ ពោធិ៍សាត់? មានដឹងស្រុកភូមិអីទេអ្នកមីង?

ខ៖ ដឹង! ម្ដុំហ្នឹងគេហៅជំណាក់ច្រក្រុំ ម្ដុំភូមិ ជំណាក់ច្រក្រុំ ម្ដុំកន្លែងអាលកសរគេផ្លូវអាលាបចុះពីអាលាបទៅ។

ក៖ អូ!

ខ៖ ហ្នឹងហើយ!

ក៖ ស្រុកខ្ញុំដែរអញ្ចឹង!

ខ៖ អញ្ចឹង!

ក៖ ហើយអ្នកមីងកាលពីនៅក្មេងៗហ្នឹងមានចងចាំពីអ៊ឺ! អនុសាវរីយ៍កាលនៅជាមួយពួកគាត់អត់?

ខ៖ ចងចាំបងប្អូនខ្ញុំរៀនទាំងអស់គ្រប់គ្នា តែងតែរៀនជាមួយគ្នាតែងតែប្រលងប្រណាំងជាមួយគ្នា ក្នុងការរៀនជាប់ចំណាត់ថ្នាក់ ពេលហ្នឹងខ្ញុំត្រូវរៀនចាញ់ប្អូន ប្អូនខ្ញុំជាប់បានសុទ្ធតែលេខមួយ ហើយខ្ញុំរៀនប្រលងចូលសុទីរីកាថ្នាក់ទី៦ អ៊ីស៊ីម៉ាស់១៨មិនាជំនាន់ហ្នឹងកំពុងតែប្រលងៗទទួលគេបាញ់លោក កែវ សុគីម ស្លាប់នៅកន្លែងសាលគេកំពុងប្រលងហ្នឹង ពួកខ្ញុំរត់ខ្ចាត់ខ្ចាយតាំងពីជំនាន់ហ្នឹងមកអត់សូវបានរៀន បែកចេញបានចូលពលពតហ្នឹងបណ្ដោយមក។

ក៖ បាទ! អ្នកមីង។ ហើយពួកគាត់ដែលពតពលយកទៅសម្លាប់ហ្នឹង សម្លាប់ជុំគ្នា ឬបែកគ្នា ឬនៅក្នុងខេត្តតែមួយ?

ខ៖ ពេលនៅជុំជាមួយគ្នាទាំងអស់ អត់មានសម្លាប់ទេប្អូនខ្ញុំដោយសារអត់បាយ ដោយសារហើម ស្លាប់ដោយសារហើមហូបតា ហូបតានិយាយចំហូបតាក្ដួច ហើយហ្នឹងអ៊ឺ! អាគល់ចេកយើងហើយនិងអាស្មៅជើងទាយើងហ្នឹងស្រោះញាំអត់មានអង្ករទេ អត់មានឲយើងបានស្គាល់រស់ជាតិអង្ករសោះ ហើយនិងអំបិលក៏អត់ដែរ។ អញ្ចឹងពួកខ្ញុំទៅរកត្រពាំង អាត្រពាំងឬស្សីព្រិកហ្នឹងហើយក្ដួចបួកនាក់បងប្អូន ប្រាំនាក់បងប្អូនទៅរក យាយខ្ញុំចាស់ៗម្ដាយខ្ញុំដូចថាគាត់ស្លត់គាត់ហាស់។

ក៖ បាទ!ៗ អ្នកមីង។

ខ៖ ម៉ាក់ខ្ញុំឲតាដល់ស្រុកគេគាត់ស្លត់គាត់គាត់សម្លប់រហូតនៅសល់តែខ្ញុំហើយយាយខ្ញុំហើយនិងប្អូនៗ ខ្ញុំរករហូតដល់យូរទៅដូចថាវាទន់ទៅខ្ញុំជាបងមុជទឹកឲយាយផងហើយតាផង មុជទឹកឲប្អូនផងទៅសំតាខ្ញុំស្លាប់ដំពេលហ្នឹងប្អូនខ្ញុំ ស្អែកឡើងប្អូនខ្ញុំអត់ដឹងអីសោះស្រាប់តែដាស់ប្អូនៗខ្ញុំទៅអស់អាលីង។

ក៖ បាទ!ៗ អ្នកមីង។

ខ៖ ហ្នឹងហើយស្លាប់នៅជំនាន់ហ្នឹង គឺស្លាប់ជំនាន់ចេញពីអាពតហើយប្រហែលជា៧៦។

ក៖ កាលបងប្អូនអ្នកមីងស្លាប់ហ្នឹងគាត់អាយុប្រហែលប៉ុន្មានៗអស់ហើយ?

ខ៖ ពីរដណ្ដប់ឆ្នាំ អាបន្ទាប់ខ្ញុំបីដណ្ដប់ឆ្នាំ ខ្ញុំប្រាំដណ្ដប់។

ក៖ អ៎!

ខ៖ ចាំ!

ក៖ បាទ! អរគុណច្រើនអ្នកមីង។

ខ៖ ហើយអាមួយតូចហ្នឹងបានប្រាំបីឆ្នាំទេអាពៅគេ។

ក៖ បាទ!ៗ អ្នកមីង។ តើម្ដាយអ្នកមីងមានឈ្មោះអ្វីដែរអ្នកមីង?

ខ៖ ឈ្មោះ ហូត យែម។

ក៖ ចុះឪពុកវិញអ្នកមីង?

ខ៖ ឪពុកខ្ញុំឈ្មោះ យិន សម្បត្តិ យិន សំអូនផង យិន សម្បត្តិ គាត់ដាក់ យិន សំអូនទៅ។

ក៖ ហើយសព្វថ្ងៃហ្នឹងពួកគាត់នៅរស់ ឬក៏ស្លាប់អស់ហើយ?

ខ៖ ស្លាប់អស់ហើយអត់មាននៅសល់ទេ។

ក៖ អញ្ចឹងពួកគាត់អ្នកមីងនៅចាំអឺ! គាត់ស្លាប់ប្រហែលជាឆ្នាំណាដែរអ្នកមីង?

ខ៖ ឆ្នាំ៧៦។

ក៖ ទាំងពីរនាក់ហ្នឹងអ្នកមីង?

ខ៖ ចាំ! ម៉ាក់ខ្ញុំស្លាប់៧៦ ប្អូនៗក៏៧៦ សល់តាអា៣៧ទេ ៧៧ នៅ៧៦ហ្នឹងគឺស្លាប់ទាំងអស់។

ក៖ នៅភូមិណា ឃុំណាដែរពួកគាត់ស្លាប់ហ្នឹង?

ខ៖ ស្លាប់ហ្នឹងនៅឃុំ ចំណាក់ច្រក្រុម កន្លែងគេជីកប្រឡាយនៅខេត្តពោធិ៍សាត់។

ក៖ អ៎! នៅពោធិ៍សាត់។

ខ៖ ចូលផ្លូវអាលាប អាលាបអញ្ចឹងហើយម៉្ដុំហ្នឹងចូលទៅដល់ភ្នំអ៊ី! គេកាត់ខ្ញុំឆ្លងស្ទឹងទៀតហាស់ ទៅដល់ហ្នឹងគេនិយាយស្លួយទៀតហ៎!

ក៖ អ៎! បាទ! អ្នកមីង។

ខ៖ ហ្នឹងហើយ!

ក៖ ចុះអ្នកមីងមានដឹងអ៊ី! ឪពុកម្ដាយរបស់អ្នកមីងគាត់ទាំងពីរហ្នឹងកើតនៅឆ្នាំណាដែរអ្នកមីង?

ខ៖ ដឹងម៉ាក់ខ្ញុំឆ្នាំ១៩៤៥ ប៉ាខ្ញុំឆ្នាំ១៩២៨។

ក៖ អ៎! បើគិតជាឆ្នាំច័ន្ទគតិវិញត្រូវជាសត្វអីដែរអ្នកមីង?

ខ៖ ប៉ាខ្ញុំឆ្នាំជូត ម៉ាក់ខ្ញុំឆ្នាំរោង។

ក៖ អ៎! គោ ហើយនិងសត្វស្វា!

ខ៖ គោ ហើយនិងកណ្ដុរ។

ក៖ អ៎! គោ ហើយនិងកណ្ដុរហាស់!!!

ខ៖ អ៎! កណ្ដុរ ហើយនិងសត្វពស់ច្រលំណា។

ក៖ ហាស់!ៗ កណ្ដុរ ហើយពស់!

ខ៖ ហ្នឹងហើយកណ្ដុរហើយនិងពស់។

ក៖ ហើយអ៊ី! ស្រុកកំណើតគាត់នៅខេត្តពោធិ៍សាត់ដែរ?

ខ៖ អត់ទេ! ប៉ាខ្ញុំនៅកោះ ដាច់។

ក៖ ខេត្ត កណ្ដាល!

ខ៖ ស្រុក កោះ ដាច់ ខេត្ត កណ្ដាល។ ម៉ាក់ខ្ញុំនៅភ្នំពេញតាំងពីដើមមក តាយាយខ្ញុំគាត់អ្នកធ្វើការនៅក្នុងវាំង។

ក៖ អ៎! គាត់អ្នកធ្វើការក្នុងវាំងដែរ!

ខ៖ ហ្នឹងហើយធ្វើការជាមួយសម្ដេច គាត់អ្នកខាងរត់ពន្ធសំបុត្រពន្ធដើមម្ចាស់ពើងគាត់អ្នកយាមតំណាក់ហ្នឹង ហើយយាយខ្ញុំអ្នកធ្វើម្ហូបថ្វាយស្ដេច។

ក៖ អ៎!

ខ៖ ហ្នឹងហើយ! ហើយខ្ញុំពួកខ្ញុំម៉ាក់ខ្ញុំគ្រូបង្រៀនសាលាស៊ីសុវត្ថិជំនាន់ពីដើម ហើយប៉ាខ្ញុំគាត់អ្នកបោះពុម្ភសៀវភៅ សាច់រឿងអីហ្នឹងតាម។

ក៖ អញ្ចឹងដូចជាអ្នកមីងទើបតែមានប្រសាសន៍មិញថាអ៊ី! ឪពុកកាលគាត់នៅរស់ហ្នឹងគាត់ប្រកបរបរអ្វីដែរ?

ខ៖ គាត់លក់សៀវភៅ បោះពុម្ភសៀវភៅសាច់រឿង។

ក៖ គាត់ជាអ្នកនិពន្ធ!

ខ៖ គាត់ជាអ្នកនិពន្ធហ្នឹង!

ក៖អ៎! កវីហើយ! គាត់រៀនបានជ្រៅជ្រះដែរអញ្ចឹង។

ខ៖ ចា៎!

ក៖ ហើយកាលគាត់នៅរស់ហ្នឹង គាត់ជាមនុស្សបែបណាដែរអ្នកមីង?

ខ៖ អត្តចរិកគាត់អ្នកស្លូតបូតណាស់ គាត់ចូលចិត្តជួយអ្នកក្រ គាត់ចូលចិត្តស្រឡាញ់បងប្អូនណាដែរក្រេ គាត់ចូលចិត្តតាប្រដៅបងប្អូនទាំងអស់ថាចេះស្រឡាញ់គ្នា យើងកុំស្រឡាញ់សាសន៍ដ៏ទៃក្រៅពីបងប្អូនយើងជួយគ្នាទៅវិញទៅមក ដល់ពេលតែគាត់ចេះតែជួយចិញ្ចឹមក្មួយៗអាប្រុសៗ ខ្ញុំនៅតូចៗអត់មានបានចិញ្ចឹមខ្ញុំទេ ខ្ញុំបានត្រឹមតែស្គាល់ហូបបន្តិចបន្តួចទេ អាក្មួយៗគាត់ គាត់យកយោងមកនៅក្នុងស្រុកនៅក្នុងផ្ទះហ្នឹងទាំងអស់ដើម្បីចាប់ពុម្ពអក្សរសៀវភៅជួយគាត់ ដើម្បីឲរៀន ស្រីៗរៀនកាត់ដេរ នែ! អាទូតចិននេះប្រុសសុទ្ធរៀនសុទ្ធតែអាំងស៊ីញើ តែឥឡូវពួកហ្នឹងក៏ស្លាប់អស់ដែរ។

កៈ បាទ!ៗ អ្នកមីង។ ចុះម្ដាយអ្នកមីងកាលគាត់នូវមានជីវិតរស់នៅ គាត់ប្រកបមុខរបរអ្វីដែរអ្នកមីង?

ខៈ គាត់គ្រូបង្រៀន។

កៈ គ្រូបង្រៀន!

ខៈ គាត់អ្នកគ្រូបង្រៀននៅសាលាស៊ីសុវត្ថិ ដោយសារគាត់បានតាយាយគាត់ធ្វើការហ្នឹង គេឲបង្រៀននៅជិតវាំងហ្នឹង។

កៈ ហើយគាត់ជាមនុស្សបែបណាដែរអ្នកមីង?

ខៈ អត្តចរិកគាត់ស្លូតបូតណាស់លោកគ្រូ។

កៈ អ៎!

ខៈ គាត់ស្លូតបូតគាត់ស្រឡាញ់ចេះអប់រំ គោរពសិទ្ធិចំពោះប្ដីចំពោះបងប្អូននិងម្ដាយឪពុក ដឹងខុសត្រូវណាស់។

កៈ តើអ្នកមីងនៅចងចាំសាច់រឿងអ្វីខ្លះៗពីឪពុកម្ដាយរបស់អ្នកមីងខ្លះៗដែរទេអ្នកមីង?

ខៈ ខ្ញុំចាំ ចាំថាប៉ាខ្ញុំ គាត់មកពីជូនណាគាត់បើកឡាន ជូនណាគាត់ជិះកង់ បើផ្លូវជិតគាត់ជិះកង់យកទៅឲគេ ពេលអ៎! គេអ្នកកម្មង់ជិតគាត់ជិះកង់ បើឆ្ងាយដូចជាទៅកោះកុងអី ឆ្ងាយៗគាត់បើកឡានទៅ។ ថ្ងៃដែលគេអាពតចូលមកហ្នឹង គាត់ក៏បែកពីខ្ញុំដែរហើយ ម៉ាក់ខ្ញុំក៏បែកពីគាត់ដែរ ហើយជីវិតពួកខ្ញុំដ៏អត់ពីម៉ែទៅដូច អស់ពីឪពុកខ្ញុំទៅតែតោខ្ញុំនៅជាមួយជីដូនដែរនៅជាមួយយាយមួយតា តែតាយាយស្លាប់អស់ទៀតប្អូនស្លាប់អស់ទៀត ខ្ញុំនៅតែឯកកោម្នាក់ឯង ហើយដល់តាពេលចេញពីអាពតមកខ្ញុំដើរតែឯងមក ខ្ញុំក៏មានម្នាក់គេក៏រើសខ្ញុំមកចិញ្ចឹមហើយដើរតាមគេរហូត រស់នៅជាមួយគេហ្នឹងដល់គេហ្នឹង គេបែកពីខ្ញុំគេមានប្ដីគេអីទេ។

កៈ បាទ!ៗ។

ខៈ ខ្ញុំក៏ដើររកអនាគតដោយខ្លួនឯងដល់សព្វថ្ងៃហ្នឹង។

កៈ បាទ!ៗ អ្នកមីង។ ចុះអ៊ឺ! ឪពុកម្ដាយអ្នកមីងធ្លាប់និយាយរឿងកាលពីពួកគាត់នៅក្មេងៗឲអ្នកមីងស្ដាប់ទេអ្នកមីង?

ខ៖ និយាយប្រាប់ថា ជំនាន់គាត់អិសារៈ គេចាប់ពួកស្រីក្រមុំៗ តាយាយខ្ញុំយកគាត់ទៅលាក់នៅក្នុង

អណ្តូងក៏មាននៅក្នុងត្រង់សេក៏មាន ជីកដីក៏មានដែរគាត់និយាយ ហើយប៉ាខ្ញុំប្រវត្តិគាត់កាលហ្នឹងគាត់បួសលោក គាត់បួសលោកគាត់ថាទំរាំគាត់បានចេះដឹងប៉ុណ្ណឹង មានគេផ្ចាញ់ផ្ចាល់សិតតាកាំបិតនៅក្នុងពាងទឹកអីចឹងណា ថាដងទឹកហូបកាំបិតនៅក្នុងពោះតែគាត់ចេះអីចឹងទៅគាត់ដឹង ជីវិតគាត់តស៊ូគាត់ធ្លាប់ធ្វើនិយាយទៅជីវិតគាត់វេទនាណាស់ពីដើមមក ជីវិតគាត់អ្នកស្រែចំការពីដើម ពីដើមមកប៉ាខ្ញុំជាអ្នកចំការ។

ក៖ បាទ!ៗ អ្នកមីង។

ខ៖ ហ្នឹងហើយ!

ក៖ តើអ្នកមីងនៅចាំឈ្មោះជីដូនជីតារបស់អ្នកមីងដែររឺទេអ្នកមីង?

ខ៖ ចាំ!

ក៖ ចាំទាំងសងខាងអ្នកមីង?

ខ៖ ចាំ!

ក៖ សូមជួយប្រាប់ឈ្មោះគាត់ផងបានដែររឺទេអ្នកមីង?

ខ៖ តាឪពុកប៉ាខ្ញុំឈ្មោះ យិន អ៊ុំ ហើយយាយខ្ញុំឈ្មោះ ជា ង៉ែត ហើយម្តាយខ្ញុំយាយខ្ញុំហ្នឹងឈ្មោះ អី សុម? អិត សុម ហើយឪពុកម៉ែខ្ញុំឈ្មោះ ហួត មោគ។

ក៖ បាទ!ៗ អ្នកមីង។

ខ៖ ចាំ!

ក៖ មានដឹងថាពួកគាត់កើតនៅឆ្នាំណាដែរអ្នកមីង?

ខ៖ ខ្ញុំប្រហែលអត់ដឹងទេ ប៉ុន្តែខ្ញុំធ្វើជាគណិតមួយដកអាយុដែលគាត់ស្លាប់ជំនាន់ពលពត ហើយខ្ញុំដកខ្ទង់ដែលគាត់ស្លាប់ហ្នឹងអាយុខ្ទង់ ៦៨តាខ្ញុំ ហើយយាយខ្ញុំអាយុ ៦៥ អញ្ចឹងខ្ញុំអាចដកគុណចែកជំនាន់ហ្នឹងមកដល់ឥឡូវ ខ្ញុំដឹងតែខ្ញុំភ្លេចហើយ។

កៈ បាទ!ៗ

ខៈ តែខ្ញុំធ្វើនូវពង្សប្រវត្តិហ្នឹង ខ្ញុំអត់ចាំទេកន្លែងហ្នឹង តែខ្ញុំដកគុណតាមអាយុគាត់ស្លាប់ហ្នឹង។

កៈ ហើយអ្នកមីងអ៊ឺ! មានដឹងថាពូកគាត់អ៊ឺ! កើតនៅកន្លែងណា? ស្រុកកំណើតគាត់ហាស់?

ខៈ តាយាយខ្ញុំហែស?

កៈ បាទ!

ខៈ យាយខ្ញុំកើតនៅកោះដាច់ តាខ្ញុំធ្វើការនៅព្រៃវែង ហើយយាយខ្ញុំគាត់អ្នកនៅពោធិ៍ចិនតុងម្ដាយខាងម៉ែខ្ញុំ ហើយតាខ្ញុំនៅខាងត្បាតពង។

កៈ អំ! ហ្នឹងហើយៗ។

ខៈ ចាំ!

កៈ ហើយអ្នកមីងធ្លាប់ដឹងរឿងខ្លះៗពីពូកគាត់ខ្លះៗទេ?

ខៈ ដឹងពីប្រវត្តិគាត់ជីវិតគាត់ពីដើម ពីដើមជីវិតគាត់អ្នកកសិករ ដើរគាត់ធ្វើស្រែលក់អង្ករទេ ដល់គាត់បានជួបខ្លើនរក្សគាត់ហ្នឹងក៏បានមកធ្វើការនៅក្នុងវាំង ក៏ចាប់ដីនៅក្នុងទីក្រុងភ្នំពេញហ្នឹងមកហ្នឹងខាងម្ដាយខ្ញុំ ហើយខាងប៉ាខ្ញុំគាត់អ្នកចំការរហូតតាំងពីហ្នឹងមក គាត់អត់មានធ្វើអីទេ។

កៈ បាទ!ៗ អ្នកមីង។ តើអ្នកមីងមករស់នៅអ៊ឺ! ភ្នំពេញហ្នឹងរយៈពេលយូរប៉ុណ្ណាហើយ? ឬក៏តាំងពីតូចមកអ្នកមីងនៅហ្នឹងហ្មង ឬក៏?

ខៈ ចាំ! តាំងពីតូចមកខ្ញុំនៅហ្នឹងហ្មង។

កៈ អំ! ដោយសារអ្នកមីងមានស្រុកកំណើតនៅហ្នឹងហ្មង អ្នកមីង?

ខៈ ចាំ! តែខ្ញុំមកដល់ទីក្រុងភ្នំពេញហ្នឹងឃើញផ្ទះខ្ញុំសុទ្ធតែខ្មោះច្រវ៉ាក់ ខ្ញុំអត់បានយកផ្ទះហ្នឹងទេ។

កៈ បាទ!ៗ។

ខៈ ដោយសារខ្ញុំឈរយុំឆ្អែតដោយសារខ្ញុំមក ទៅដប់ប្អូននាក់មកវិញឃើញខ្ញុំម្នាក់ឯង ហើយខ្ញុំឃើញដីទូកៗ ផ្លូវចូលហើយឃើញសុទ្ធតែខ្មោះ

ខ្ញុំមិនអាចនៅកើតទេបាត់បង់ម្ដាយឪពុក ខ្ញុំក៏គេអ្នកនាំខ្ញុំមកផ្ទះហ្នឹងហ៎ា! ហើយគេក៏យកខ្ញុំទៅវិញទៅហើយមកនៅពោធិ៍ចិនតុងវិញមក។

កៈ បាទ!ៗ អ្នកមីង។

ខៈ ហ្នឹងហើយ!

កៈ អញ្ចឹងអ្នកមីងបងប្អូនអីស្លាប់អស់ហើយនៅសល់អ្នកមីងម្នាក់។

ខៈ ចាំ!

កៈ ហើយអ្នកមីងអត់មានសាច់ញ្ញាតិអីនៅក្រៅប្រទេសទេណា?

ខៈ អត់មានទេ។

កៈ ចុះកូនអ្នកមីងទើបតែរៀបការហ្នឹង?

ខៈ គេទឹមតែចេញទៅហ្នឹង។

កៈ គាត់នៅណាវិញ?

ខៈ ញ៉ូហ្សាលែន!

កៈ ញ៉ូហ្សាលែន! តើស្វាមីរបស់អ្នកមីងមានឈ្មោះអ្វីដែរអ្នកមីង?

ខៈ ឈ្មោះអឺ! សៅ សំអឿន។

កៈ តើអ្នកមីងបានរៀបអាពាហ៍ពិពាហ៍នៅពេលណាដែរអ្នកមីង?

ខៈ ខ្ញុំរៀបជាមួយគាត់ជំនាន់ ១៩៨៥។

កៈ អ្នកមីងមាននៅចាំថ្ងៃ ខែ អីទេ?

ខៈ មានដែរតើ តែខ្ញុំ ខ្ញុំអត់ចាំទេ តែដឹងតាខ្ញុំថ្ងៃខ្ញុំកើតឆ្នាំ រៀបចំហ្នឹងឆ្នាំ ១៩៨៥អីហ្នឹង។

កៈ តែអត់ចាំខែទេ?

ខៈ ចាំ!

កៈ ហើយអាពាហ៍ពិពាហ៍របស់អ្នកមីងហ្នឹងត្រូវរៀបចំឡើងដោយឪពុកម្ដាយ ឬក៏មិនមែនទេអ្នកមីង?

ខ៖ ដោយម្ដាយមីងរបស់ខ្ញុំ ប្អូនប៉ាខ្ញុំគាត់រៀបចំធ្វើម៉ែឪ។

ក៖ មិនមែនពលពតអ្នកចាប់បង្ខំអីទេ?

ខ៖ អត់ទេ!

ក៖ ហើយការរៀបអាពាហ៍ពិពាហ៍ហ្នឹង មានទាថ្លៃជំនូនគេទេអ្នកមីង?

ខ៖ ទេខ្ញុំអត់ដឹងទេជំនាន់ហ្នឹងលើមាមីងខ្ញុំ ខ្ញុំអត់ដឹងសោះ។

ក៖ តែគេមានយកថ្លៃជំនូនតើកាលហ្នឹង?

ខ៖ ហ្នឹងហើយយកជំនូនអីបន្តិចបន្តួច ទិញកាត់ខោអាវជំនាន់ហ្នឹងទើបចេញពីអាពតមកដែរ។

ក៖ បាទ!ៗ អ្នកមីង។

ខ៖ ដូចអត់សូវមានសម្ភារៈអីណាស់ណាដែរ។

ក៖ តើអ្នកមីងអាចប្រាប់ក្មួយពីពេលដំបូងដែលធ្វើឲអ្នកមីងហើយស្វាមីបានជួបគ្នាបានដែរទេបាទ?

ខ៖ បាន!

ក៖ សូមអ្នកមីងជួយប្រាប់ត្រួសៗ។

ខ៖ ពីមុនខ្ញុំធ្វើការនៅអនុខណ្ឌជាប្រធានសមាគមន៍យុវជននារី ខ្ញុំនៅជាមួយគេដ៍អញ្ចឹងគេហ្នឹងក៏ ខ្ញុំបានធ្វើជាសមាគមន៍យុវជនមួយដើម្បីដឹកនាំគេទៅកាន់វ៉ែកប្រាំជំនាន់ហ្នឹងហាស់ហើយដល់តាពេលហ្នឹងខ្ញុំត្រលប់មកវិញក៏មានបញ្ហាដូចថា ក្នុងខណ្ឌសង្កាត់ប្រជាជនដូចថាចេះតែយើងបំផុសចលនាយុវជន គេខ្លាចកូនគេជំនាន់ហ្នឹងខ្លាចធ្វើទាហានទាអីទៀតនោះ ខ្ញុំក៏លាតំណែងឈប់ធ្វើការហ្នឹងក៏ឈប់ធ្វើការហ្នឹងខ្ញុំក៏ទៅធ្វើការ ការហ្នឹងជំនាន់ហ្នឹងក៏ខ្ញុំលាតំណែងហ្នឹង អនុខណ្ឌគេឲរើសមួយខណ្ឌមួយសង្កាត់ដើម្បីអ្នកទៅរៀនសិមដេរីលេ បុណ្យព្យុះហៈយាត្រាបុណ្យ៧មករាហ្នឹងហាស់ ៧មករាខ្ញុំក៏មកប្រលាន មកប្រលានកំពង់ឆ្នាំងយើងហ្នឹង មកប្រលានកំពង់ឆ្នាំងខ្ញុំក៏បានជួបគាត់នៅពេលហ្នឹងទៅចំពេលហ្នឹងគាត់ក៏ធ្វើទាហ៊ាន ខ្ញុំក៏លប់មកវិញពីកន្លែងប្រលានយន្តហោះសិមជើងបុណ្យ៧មករាចប់ តា កែ សន្តាក៏យកឲខ្ញុំធ្វើខាងកាត់ដេរនៅ៧មករានៅអូឫស្សី។

ក៖ អូ! អ្នកមីងចេះកាត់ដេរដែរ?

ខ៖ ចាំ! កាត់ដេរនៅអូឫស្សីដេរខោអាវទាហ៊ានទេកាលហ្នឹង អ្នកណាដេរខោ ខោទៅ អ្នកណាដេរអាវ អាវទៅហើយក៏បានជួបគាត់ហ្នឹងគាត់មកបើកខោអាវពួកទាហ៊ានពីកន្លែងខ្ញុំទើបជួបគ្នា គាត់ក៏កូនកំព្រាដែរអត់មានម៉ែឪទេ។

ក៖ បាទ!ៗ អ្នកមីង។

ខ៖ ហ្នឹងហើយខ្ញុំក៏អត់មានម៉ែឪដូចគ្នា គាត់មានប្អូនតែគេមានបងប្អូនគេច្រើន ខ្ញុំអត់ខ្ញុំមានតែម្នាក់ឯង ហើយខ្ញុំក៏បានជួបគ្នាដោយសេចក្ដីស្រឡាញ់ហ្នឹងដោយសារបងប្អូនគេចូលទៅបងប្អូនខ្ញុំទៅ។

ក៖ បាទ!ៗ អ្នកមីង។ ហើយចុះអ្នកមីងអឺ! បានរៀនភាសាខ្មែរហ្នឹងបានកំរឹតណាដែរអ្នកមីង?

ខ៖ ខ្ញុំថ្នាក់ទី៦។

ក៖ ថ្នាក់ទី៦!

ខ៖ ចាំ!

ក៖ ហើយអឺ! សាលារៀនដែរអ្នកមីងទៅរៀនហ្នឹង កាលហ្នឹងនៅណាដែរអ្នកមីង?

ខ៖ នៅម្ដុំគុគទួលស្លែងហ្នឹងហ៊ុង។

ក៖ សាលាហ្នឹងមានឈ្មោះអីដែរអ្នកមីង?

ខ៖ ពីមុនគេហៅសាលាឥន្ទ្រៈទេវី ដល់តាខ្ញុំលើដល់ស៊ីទីវីកាថ្នាក់ទី៦ សាលាហ្នឹង១៨មិនា។

ក៖ អ៎! អញ្ចឹងមិនមែនឥន្ទ្រៈទេវីនៅក្បែរនេះណា?

ខ៖ អត់ទេ ពីមុនកន្លែងហ្នឹងឥន្ទ្រៈទេវី។

ក៖ អ៎! បាទ! អ្នកមីង។ តើអ្នកមីងមានអឺ! មិត្តភ័ក្រស្និទស្នាលដែលធំធាត់ជាមួយអ្នកមីងដែរទេកាលហ្នឹង? ធំឡើងហ្នឹង? អញ្ចឹងអត់សូវមានមិត្តភ័ក្រទេអ្នកមីង!

ខ៖ អត់សូវមានភក្រ័!

កៈ បាទ!ៗ អ្នកមីង។

ខៈ មានមួយកាលនៅរៀន គេខាងកូនតុលាការកាត់ក្ដី តែឥឡូវហ្នឹងគេមិនដឹងស្លាប់មិនដឹងរស់បែករហូត គ្មានមិត្តភ័ក្រ្កទាំងអស់។

កៈ បាទ!ៗ អ្នកមីង។

ខៈ ចាំ!

កៈ អឺ! អ្នកមីងពីមុនៗមកអ្នកមីងប្រកបការងារអ្វីដែរអ្នកមីង?

ខៈ ដូចខ្ញុំនិយាយអញ្ចឹងពីមុនខ្ញុំកាត់ដេរ៧មកវាហ្នឹងហើយ ខ្ញុំពីមុនធ្វើការនៅអនុខណ្ឌធ្វើទៅវាចេះតែ!

កៈ ចុះឥឡូវអ្នកមីង អ្នកមីងមានការងារអីដើម្បីប្រកបចិញ្ចឹមជីវិតហាស់?

ខៈ អត់នៅមើលចៅ។

កៈ នៅមើលចៅ! តើតាំងពីវ័យក្មេងរហូតដល់ពីនេះ តើជីវិតរបស់អ្នកមីងមានការផ្លាស់ប្ដូរអ្វីខ្លះដែរអ្នកមីង?

ខៈ ផ្លាស់ប្ដូរក្នុងជីវិតខ្ញុំ កាលនៅពីក្មេងខ្ញុំហាត់ហើយខ្ញុំអត់ ខ្ញុំមានប្ដីហើយប្ដីខ្ញុំស្លាប់ទៅ ខ្ញុំនៅចិញ្ចឹមកូនតែឯងដល់តាកូនបានធំៗហើយក៏ខ្ញុំនៅតែពិបាក
នេះជាការរស់នៅទីពឹងមិនបានដោយសារ ខ្ញុំគ្មានស្អីសំរាប់ ឲកូនចៅ ចែករបស់ឲកូនអញ្ចឹងកូនចេះតែពិបាកអស់អញ្ចឹងទៅ។

កៈ បាទ!

ខៈ ហើយខ្ញុំនៅតែរស់ជួលតែផ្ទះគេរហូតដោយសារតែ ខ្ញុំមានសេចក្ដីមួយកោតខ្លាចថាមិនចង់បានរបស់គេ
ទីមួយខ្លាចជំនាន់ហ្នឹងនឹកឃើញមិនចង់បានអ្វីទាំងអស់ខ្លាចអាពតមួយសារទៀតនិយាយឲចំ ហ៊្មងជំនាន់ហ្នឹង។

កៈ បាទ!ៗ។

ខៈ ខ្ញុំអត់ចង់បានអ្វីទាំងអស់ ខ្លាចគេសម្លាប់អញ្ចឹងហ៊្មង។

កៈ អឺ! តើអ្នកមីងមានម្ហូបណាដែរអ្នកមីងចូលចិត្តទេអ្នកមីង?

ខ៖ ខ្ញុំហែ!

ក៖ ម្ហូបហាស់?

ខ៖ ម្ហូបដែលខ្ញុំហូបចូលចិត្តមានតែប្រហុក និងស្លរម្ជូរប៉ុណ្ណឹង។

ក៖ ប្រហុក ហើយនិងសម្លរម្ជូរ?

ខ៖ ចាំ!

ក៖ ចុះអុំ! ល្បែងប្រជាប្រិយវិញអ្នកមីង?

ខ៖ ខ្ញុំអត់ចេះទេ។

ក៖ អត់ចូលចិត្តល្បែងប្រជាប្រិយទេហែ?

ខ៖ អត់ ប្រជាប្រិយមិចដូចបៀរអីហ្នឹងហែ?

ក៖ ដូចជាល្បែងប្រជាប្រិយ ឈូង បោះអង្គុញអី!

ខ៖ អុំ! ខ្ញុំលេងដែរអញ្ចឹង ខ្ញុំចូលចិត្តកាលហ្នឹង កាលហ្នឹងនៅពីក្រមុំចូលចិត្តតែច្រៀង។

ក៖ អូ! អ្នកមីង!

ខ៖ ហ្នឹងហើយ! ចូលចិត្តច្រៀងលេង ពិបាកមែនដោយសារខ្ញុំក្រមុំដូចថាជំនាន់ខ្ញុំហ្នឹងដូចគ្មានពេលសប្បាយទេ អឺ! ចេញពីអាពតមកណាមួយនឹកឃើញខ្លួនឯងដូចថាវាតែតោរផង។

ក៖ បាទ!ៗ អ្នកមីង។

ខ៖ ហ្នឹងហើយដូចមានអារម្មណ៍មួយគ្មានការសប្បាយសោះ។

ក៖ តើអ្នកមីងចងចាំចម្រៀងណាដែលអ្នកមីងបានរៀនតាំងពីក្មេងរហូតដល់ពេលនេះដែរឬទេអ្នកមីង?

ខ៖ ច្រៀងបទ ចេះបទមួយបទមេឃមីស្រទុំ។

ក៖ អាហ្នឹងអ្នកនិពន្ធអ្នកណាគេវិញអ្នកមីង?

ខ៖ អត់ដឹងទេ ខ្ញុំអត់ដឹងសោះ។

ក៖ អត់ដឹងអ្នកណាទេ ចេះតែបទហ្នឹង!

ខ៖ ដឹងតា រស់ សេរីសធាច្រៀង!

ក៖ អ៎! រស់ សេរីសធា!

ខ៖ ហ្នឹងហើយ!

ក៖ បទអ្នកមីង រស់ សេរីសធា។

ខ៖ ហ្នឹងហើយ!

ក៖ ហើយនៅក្នុងក្រុមគ្រួសារអ្នកមីងមានអ្នកណាគេចេះលេងឧបករណ៍ភ្លេងទេអ្នកមីង?

ខ៖ ដូចជាអត់។

ក៖ អត់មាន។ ដូចជាផ្ទះអ្នកមីងរស់នៅសព្វថ្ងៃហ្នឹងជួលគេអ្នកមីង?

ខ៖ ចា៎! ជួលគេ។

ក៖ ផ្ទះឈើ ឬក៏ផ្ទះអី?

ខ៖ ផ្ទះថ្ម។

ក៖ ផ្ទះថ្ម។ តើអ្នកមីងមានអ៎! ជំនាញអ្វីខ្លះដែលត្រូវបានរៀនបន្តវេនពីក្រុមគ្រួសាររបស់អ្នកមីង ដូចជា ជំនាញវេញវល្លិ៍ផ្តៅ ជំនាញក្នុងការធ្វើស្កររត្នោត។ល។?

ខ៖ ខ្ញុំអត់ចេះសោះ ខ្ញុំអត់ចេះ។

ក៖ មានជំនាញអីដែលរៀន?

ខ៖ ចេះតែកាត់ដេរ។

ក៖ រៀនពីឪពុកម្តាយអី តាយាយអីមក?

ខ៖ អត់ៗ តាយាយក៏អត់ ដូចថាខ្ញុំនិយាយអញ្ចឹងគឺថាខ្ញុំកើតមកក្នុងទីក្រុងភ្នំពេញ។ ប៉ាខ្ញុំអ្នករៀនម៉ាក់ខ្ញុំអ្នករៀនអញ្ចឹង ខ្ញុំអត់បានចេះអីទាំងអស់។

ក៖ អត់បានលួចរៀនអីពីគាត់ទេអី?

ខ៖ ចេះតាចាក់ចេះ ចាក់ខោអាវរៀននៅក្នុងសាលារៀន គេបង្រៀនឲចេះចាក់អាវ ចាក់កន្ទ្រក ចាក់អ៊ី! កំរាលអីហ្នឹងចេះ។

ក៖ តែអត់មានឪកាសរៀនពីត១ ពីប៉ាម៉ាក់យើង គាត់អត់មានផ្ទេរអី?

ខ៖ អត់មានអត់អីទាំងអស់។

ក៖ អ៎! តាមពិតជំនាញពួកគាត់ល្អ១តើអ្នកមីង។

ខ៖ គាត់គ្រាន់តែប្រដៅឲខ្ញុំថា កូនអើយខំរៀនចេះពីរៀនមានពីរក បើកូនឯងចង់ឆ្ងាញ់ទាល់តែរកអន្លូក គាត់ចេះតាប៉ុណ្ណឹង គាត់ប្រាប់ដាក់កំនាព្យនិងក្ដា។

ក៖ បាទ!១។ តើអ្នកមីងអាចប្រាប់ខ្ញុំពីពេលវេលា ដែលលំបាកនៅក្នុងជីវិតរបស់អ្នកមីងបានដែរឬទេ? ដូចថាតាំងពីតូចរហូតដល់ប៉ុណ្ណឹង អ្នកមីងគិតថា កំឡុងពេលណាដែលអ្នកមីងគិតថាលំបាករស់នៅ?

ខ៖ និយាយឲចំចាប់តាំងពីខ្ញុំដឹងក្ដីមករហូតដល់សព្វថ្ងៃហ្នឹង គឺខ្ញុំស្គាល់ជីវិតតែទុក្ខលំបាកហាត់នឿយរហូត គឺថាខ្ញុំអស់ទីពឹង ទោះបីខ្ញុំនៅពីតូចក៏ខ្ញុំគ្មានបានអីគឺថា ស្គាល់រស់ជាតិអី ឬក៏សប្បាយហ្នឹងគេដែរដោយសារខ្ញុំនៅតូច១ ដ៏ខ្ញុំបានរស់ដឹងក្ដីចេញពីអាពតមក កាលនៅអាពតក៏ខ្ញុំវេទនាហាត់នឿយដែរ កាលអាពតវាវីសតែរៀបនឹងសម្លាប់ខ្ញុំ គេឲខ្ញុំជីកដីហើយកប់ត្រឹមក ពេលហ្នឹងខ្ញុំឃ្លានពេកខ្ញុំក៏ទៅចាប់កូនក្អាត់ចាប់អីអញ្ចឹងយកមកឲប្អូនហូបហាស់។

ក៖ បាទ!១។

ខ៖ ដល់តាពេលមកវិញអត់ទាន់ធ្វើការ គេឲខ្ញុំជីកដីកប់ខ្លួនឯងតែចៃដន្យអីដូចថាជីវិតខ្ញុំអត់ទាន់អស់ក៏ ថ្ងៃហ្នឹងគេហៅទៅប្រជុំ ក៏គេលើកកាត់ខ្ញុំចោលទៅ ក៏គេលើកខ្ញុំមកវិញមក គេឲខ្ញុំប្រែចិត្តឈប់ទៅយកអី១ ពេលម៉ោងជិតដល់ម៉ោងអត់ឲយើងទៅចាប់អី១ហូបទេ។

ក៖ បាទ!១ អ្នកមីង។

ខ៖ ចាំ!

ក៖ ហើយតើនៅពេលអ្នកមីងជួបភាពពិបាកអញ្ចឹង អ្នកមីងធ្វើការតាំងចិត្តយ៉ាងមិចដើម្បីឆ្លងវារួច?

ខ៖ ធ្វើការតាំងចិត្តតស៊ូក្នុងជីវិតដើម្បី ខ្ញុំនឹកឃើញថាម្ដាយឪពុកបងប្អូនស្លាប់អស់ហើយសល់ម្នាក់ បើសិនជាខ្ញុំមិននៅម្នាក់សំរាប់តស៊ូក្នុងវង្សត្រកូលតពូជទេ គឺខ្ញុំត្រូវបាត់បង់ពូជវង្សត្រកូលហ្នឹងគ្មានអ្នកណាដឹងលឺ អត់មានកូនចៅតពូជហ្នឹងគេអញ្ចឹងណា។

ក៖ បាទ!ៗ។ តើអ្នកមីងមានបទពិសោធន៍ណាខ្លះដែលល្អៗ ក្នុងជីវិតរបស់អ្នកមីងទេអ្នកមីង? ដូចថាតាំងពីក្មេងរហូតដល់ពេលនេះ មានពេលវេលាណាដែលអ្នកមីងគិតថាសប្បាយចិត្ត ដូចជាពេលឃើញកូនរៀបអាពាហ៍ពិពាហ៍អី?

ខ៖ ពេលកូនរៀបអាពាហ៍ពិពាហ៍សប្បាយចិត្ត តែក្នុងអារម្មណ៍របស់ខ្ញុំពិបាកចិត្ត ទីមួយយើងអត់ ទីពីរយើងពិបាកក្នុងការខ្លាចការហើយជំពាក់គេ។

ក៖ បាទ!ៗ អ្នកមីង។

ខ៖ ហ្នឹងហើយ! ដោយសារយើងគ្មានទីៗ។

ក៖ តែទោះជាយ៉ាងណាក៏យើងសប្បាយចិត្តឃើញកូនចៅមានគ្រួសារអីដែរអ្នកមីង។

ខ៖ ចា៎! មានគ្រួសារ ប៉ុន្តែនូវខ្វះការសប្បាយតែបើចិត្តខ្ញុំបំណងខ្ញុំ ពេលនៅក្នុងជីវិតខ្ញុំហាត់ ខ្ញុំចិញ្ចឹមកូនអត់ពីប្ដីទៅ ខ្ញុំប្រឹងថាឲកូនធំមានតំរិះ គ្មានទ្រព្យសម្បត្តិចែកវា គ្មានតំរិះចែកវាឲវាខំប្រឹងរៀនវាខំមែន ប៉ុន្តែជីវិតខ្ញុំថាបើសិនជាកូនខ្ញុំ ខ្ញុំចាំពាក្យសម្ដីកូនខ្ញុំថា ម៉ាក់ម៉ាក់ឯងតាខ្ញុំបានរៀនសូត្របានធ្វើការចេះដឹង ម៉ាក់ឯងលែងពិបាកហត់ហើយ ខ្ញុំចាំពាក្យនេះទុកជានិច្ច។

ក៖ បាទ!ៗ។

ខ៖ តែដល់តាពេលកូនខ្ញុំបានរៀនសូត្រចេះដឹង បានការងារធ្វើគេនាំគ្នាយកដៃគូរអស់អាលីង អត់មានបានចិញ្ចឹមម៉ែសោះ បានខ្ញុំនឹកតូចចិត្តអញ្ចឹងជីវិតខ្ញុំនៅតែរកស៊ីចិញ្ចឹមអានាក់ក្រោយតូចៗដដែល។

ក៖ បាទ!ៗ។

ខ៖ ដល់ពេលវាអត់ពិបាកស៊ីរត់មករកយើងអញ្ចឹងដដែល។

ក៖ បាទ!ៗ អ្នកមីង។

ខ៖ អញ្ចឹងបានថាជីវិតយើងស្គាល់តែទុក្ខលំបាករហូត។

ក៖ នៅពេលដែលអ្នកមីងវ័យក្មេង តើអ្នកមីងធ្លាប់មានសង្ឃឹមចង់បាន ឬក៏ចង់ធ្វើអ្វីដែរហើយពេលអ្នកមីងធំឡើងសម្រេចដូចបំណងប្រាថ្នាទេអ្នកមីង?

ខ៖ អត់។

ក៖ បាទ! បើសិនជាអ្នកមីងអាចផ្តាំអ្វីមួយទៅកាន់កូនចៅជំនាន់ក្រោយៗ តើអ្នកមីងនឹងប្រាប់អ្វីខ្លះទៅកាន់ពួកគាត់? ដូចជាបណ្តាំអ្នកមីងចង់ផ្តាំទៅកាន់ពួកគាត់ហាស់?

ខ៖ អ្វីដែលខ្ញុំមុនស្លាប់ដែលខ្ញុំផ្តាំចុងក្រោយ ខ្ញុំថាអាកូនដែលមានកំហុស ដែលមានអំពើបាប ដែលមានសេចក្តីទទួលដំណឹងល្អពីព្រះហើយ សូមឲកូនឆាប់ប្រែចិត្តវិលមករកទ្រង់វិញ ទោះបីយើងដើរនៅផ្លូវខុសខាងលោកិយ គ្មានអ្នកណាក្រៅពីព្រះអង្គព្រះជាម្ចាស់ទេ ទ្រង់អាចប្រទាន់ប្រោសសង្គ្រោះយើងបាន បើសិនជាយើងកូននៅតែធ្វើអញ្ចឹង អានេះដូចខ្ញុំតែងតែនិយាយថា អត់ខុសពីលេយូ ហើយនិងឪពុកលេយូហ្នឹង ពេលគាត់ស្លាប់ទៅគាត់សម័យឃើញតែកូន កូនខ្លះមិនបានដើរតាមទទួលស្គាល់ពីព្រះអង្គជាព្រះហាស់ ទទួលដឹងហើយតែអត់ព្រមទទួលថាការពិតហាស់។

ក៖ បាទ!ៗ អ្នកមីង។

ខ៖ ហ្នឹងហើយ! ហើយខ្ញុំនូវមានអារម្មណ៍ហ្នឹងៗភ័យ ពេលខ្លះជីវិតខ្ញុំនឹងអស់ម៉ោងណាស្មាម៉ាន បើឃើញកូនខ្ញុំម្នាក់ៗអត់មានឃើញប្រែចិត្តមករកទ្រង់វិញ។ ខ្ញុំតែងតែបារម្ភក្នុងចិត្តថា ឆាប់ទៅឆាប់ប្រែចិត្តទៅ ឆាប់វិលមករកទ្រង់វិញទៅ កន្លែងដែលមានកន្លែងជ្រកកោនមានតែកន្លែងព្រះអង្គជាព្រះទេ ទោះជាពិបាកក៏ដោយស្រណុកយ៉ាងណាក៏មានសេចក្តីរស់ដោយសេចក្តីសុខសាន្តស្ងប់ក្នុងជីវិត ស្លាប់ទៅក៏យើងមានសុខដែរ។

ក៖ បាទ!ៗ អ្នកមីង។

ខ៖ ខ្ញុំមានតែប៉ុណ្ណឹង ខ្ញុំផ្តាំកូនខ្ញុំថា បើចង់ស្រឡាញ់ម៉ែសូមឲកូនបានមកព្រះវិហារគ្រប់គ្នាឲម៉ែបានឃើញពេលអញនៅរស់ កុំឲបានម៉ែឃើញសប្បាយក្នុងក្តីអំណរការសេចក្តីដំណឹងល្អរបស់ទ្រង់ដែល បានបង្រៀនឲដឹងការពិត គម្ពីរណាដែលអាចចាំមកទុកតែងតែចែកឲកូនស្តាប់ថានេះ

ហើយជាព្រះបានប្រទានពរទៅឲ       យើងប្រែចិត្តទៅឲ្យចផុតពីអំពើបាប ព្រះអង្គនូវតាអភ័យទោសដល់យើងជានិច្ច។

ក៖ បាទ!

ខ៖ តែបើយើងមិនព្រមប្រែចិត្តនោះទេ នោះជីវិតយើងគ្មានកន្លែងសុខសាន្តរស់នៅជាមួយព្រះអង្គទេ ខ្ញុំតែងតែនិយាយអញ្ចឹង។

ក៖ បាទ!ៗ អញ្ចឹងអរគុណច្រើនអ្នកមីងដែលបាន ជួបពិភាក្សាជាមួយនឹងក្មួយអ្នកមីង។

ខ៖ ចាំ!

ក៖ ហើយមុននឹងបញ្ចប់ប្រហែលជាក្មួយសំថតរូប អ្នកមីងទុកជាអនុសាវរីយ៍។

ខ៖ ចាំ!

ក៖ តើអ្នកមីងអនុញ្ញាតឲក្មួយធ្វើការដាក់រូបថត និងបទសម្ភាសនេះលើគេហទំព័ររបស់សាកលវិទ្យាល័យ Brigham Young បានដែរឺទេអ្នកមីង?

ខ៖ បានតើ!

ក៖ ហើយគេហទំព័រហ្នឹងវាមានឈ្មោះថា www.cambodianoralhistories.byu.edu អញ្ចឹងអ្នកមីងអ៊ី! បើសិនជាថ្ងៃណាមួយកូនៗ អ្នកមីងចង់ប្រវត្តិអ្នកមីងខ្លះៗ ពួកគេអាចចូលទៅក្នុងគេហទំព័រហ្នឹង គេនឹងអាចស្តាប់សំលេងដែលក្មួយបានសម្ភាសអ្នកមីង។

ខ៖ នៅក្នុងទូរស័ព្ទ?

ក៖ បាទ! នៅក្នុងទូរស័ព្ទក៏អាចស្តាប់បានដែរ។

ខ៖ អញ្ចឹងប្រធានអាចកត់អាហ្នឹងបានឲខ្ញុំតិចមើល។

ក៖ បានអ្នកមីង អញ្ចឹងអរគុណច្រើនអ្នកមីង។

ខ៖ ចាំកត់អា ដាប់បើយូៗឲខ្ញុំផង។

ក៖ បាទ!ៗ ហើយក្មួយមានតែប៉ុណ្ណឹង ហើយសូមជំរាបលាសិនអ្នកមីង។

ខ៖ ចាំ!ៗ។